**Cambodian Mekong University**

*Is the university that cares for the value of education*

# HU101 (3 Credits): English Literature I

## Purpose and Goals

This course is essentially about thinking and writing. We study authors and work from some famous world authors. Course goals emphasize developing familiarity with important authors and works from ancient to contemporary, appreciation of literature's function in expressing and embodying history, culture, society etc. This course will also allow us to explore various literary genres and devices, as well as methods of literary interpretation. By the end of the semester students will: be aware of and enjoy the richness and depth that literature offers for understanding our world, be familiar with the basic descriptive terms of literature, be aware of and pursue different methods of analysis and interpretation applied to literature, be able to express those interpretations and understandings, and persuasive argumentative essays. The fundamental aim of the course is to develop skills that can be used both for and beyond literature in analytical thinking and, most importantly, persuasive argumentative writing.

## Course Requirements

### Materials:

Selected reading of fables, classics, and human interest from various famous authors in the world. All these reading passages quoted from the story by famous authors such Shakespeare, Aesop, Charles Dickens and Erich Segal.

1. The Town Mouse and the Country Mouse (by Aesop)
2. Androcles (by Aesop)
3. The Tempest (by Shakespeare)
4. Hamlet (by Shakespeare)
5. Love Story (by Erich Segal)
6. David Copperfield (by Charles Dickens)

Students are expected to complete assigned readings prior to their discussion in class. The class schedule and a list of the assigned readings follow the grading policy.

Supplementary Materials: Other literature books are recommended to read *but* not required for this course.

## Readings:

All students are expected to read the assigned chapters in the text or any material before class. The class schedule and a list of the assigned readings follow the grading policy. As the semester progresses, I will supplement more handouts that are to be read prior to every class or discussion. If you miss class some interesting things may also slip away. Students also have to read and research for their homework or assignments. Plan yourself and time carefully from the very beginning of the course before you countering read shocks or frightening.

## Contact hours and teaching methods:

HU101 course is full time and normally consists of 48 contact hours over the sixteen-week period, taking the form of 32 hours of lectures and 16 hours of tutorial classes.

- The lecture will occupy two hours per week and tutorial classes conduct in one hour per week.
- Small class groups supplement tutorials in which they are an opportunity to work through problem sets, case studies, presentation and/or discuss seminar papers.

## Grading Policy

During English Literatures course students will be assigning to join group-work. Homework assignment will be done individually and 10% will be given. Attendance and participation are very important and 10% of your total sore will be given. If you need to be absent due to any reason, please notify your lecturer or school administrator in order for make up assignment can be given. Your grades are based on:

| | |
|---|---|
| 1. Class Participation (attendant 3%, moral 3%, and activities 4%) | 10% |
| 2. Group Presentation | 10% |
| 3. Group Assignment (and group discussion during each lesson) | 10% |
| 4. Individual Assignment/Homework Assignment (3 assignments) | 10% |
| 5. Mid-Term Test | 30% |
| 6. Final Exam | 30% |
| Total: | 100% |

## Course Outline

| Week | Story | Contents | Other |
|---|---|---|---|
| Week 1 | **Story One: The Town Mouse and the Country Mouse** | I. Orientation<br><br>II. Reading Fables by Aesop<br>The Town Mouse and the Country Mouse | |
| Week 2 | **Story Two: Androcles** | Reading Fables by Aesop Androcles | |
| Week 3 | **Story Three: The Tempest** | Reading Classics by Shakespeare<br>The Tempest<br>_ Chapter 1: A frightening storm<br>_ Chapter 2: Prospero's storm<br>_ Chapter 3: The Island<br>_ Chapter 4: Ariel | |
| Week 4 | | _ Chapter 5: Marinda falls in love<br>_ Chapter 6: Murderers<br>_ Chapter 7: Three foolish people<br>_ Chapter 8: At Prospero's cave<br>_ Chapter 9: Leaving the island<br>_ Summary | |
| Week 5 | **Story Four: Hamlet** | Reading Classics by Shakespeare Hamlet<br>_ Chapter 1: The unhappy Prince<br>_ Chapter 2: The ghost's secret<br>_ Chapter 3: Hamlet's madness<br>_ Chapter 4: The play | |
| Week 6 | | _ Chapter 5: The unhappy Prince<br>_ Chapter 6: The King's plan<br>_ Chapter 7: A new grave<br>_ Chapter 8: The truth is Known | |
| Week 7 | **Story Five: Love Story** | Reading of Human Interest<br>Love Story by Erich Segal<br>_ About the author<br>_ Chapter 1: Stupid and rich, clever and poor<br>_ Chapter 2: Blood and stone | |
| Week 8 | | _ Chapter 3: We belong together<br>_ Chapter 4: Two different Kinds of father | |

| | | | |
|---|---|---|---|
| Week 9 | | _ Chapter 5: The first three years<br>_ Chapter 6: Money can't buy everything<br>_ Chapter 7: Some men don't cry | |
| Week 10 | **Story Six:<br>David Copperfield** | **Mid Term Examination** | |
| | | Reading of Classics by Charles Dickens<br>David Copperfield<br>_ About the author<br>_ The back cover and story introduction | |
| Week 11 | | _ Chapter 1: David Copper field's childhood<br>_ Chapter 2: David is sent away to school | |
| Week 12 | | _ Chapter 3: David the orphan<br>_ Chapter 4: David and his aunt | |
| Week 13 | | _ Chapter 5: David meets old friends again<br>_ Chapter 6: David falls in love | |
| | | **Assignment Due date** | |
| Week 14 | | _ Chapter 7: Good news and bad new for David<br>_ Chapter 8: David's new life | |
| Week 15 | | _ Chapter 9: David gets married<br>_ Chapter 10: David and discovery | |
| Week 16 | | _ Chapter 10: David and discovery (Continue)<br>David Copperfield by Charles Dickens<br>_ Summary | |
| Week 17 | | **Final Examination** | |

# សាកលវិទ្យាល័យមេគង្គកម្ពុជា

ជាសាកលវិទ្យាល័យដែលយកចិត្តទុកដាក់ពីតំលៃនៃការអប់រំ

# HU101(៣ ក្រេឌីត): អក្សរសាស្ត្រអង់គ្លេស ១

## ការរៀបរាប់មុខវិជ្ជា

គោលបំណងនៃការសិក្សាអក្សរសាស្ត្រអង់គ្លេសៈ មេរៀននេះមានសារៈសំខាន់ដោយផ្តោតទៅលើការគិត វិភាគ និងសំណេរ។ យើងនឹង សិក្សាអំពីអ្នកនិពន្ធអក្សរសាស្ត្រ និងស្នាដៃអក្សរសាស្ត្រល្បីៗនៅក្នុងពិភពលោក តាំងពីសម័យបុរាណមកដល់សម័យទំនើប។ រឿងល្បើក (Fables) ដែលមានតួអង្គជាសត្វ អក្សរសិល្ប៍បុរាណ (Classics) ដែលបង្កប់នូវអត្ថន័យដ៏ប្រសើរ និងមានតំលៃគ្រប់សម័យកាល និងរឿងប្រលោមលោក ដែលបង្ហាញពីជីវិតពិតបានជ្រើសរើសយកមកសិក្សានៅក្នុងវគ្គនេះ។ តាមរយៈការសិក្សានេះ ប្រភេទសំខាន់ៗនៃអក្សរសាស្ត្រពាក្យគន្លឹះនិងវាក្យសព្ទអក្សរសាស្ត្រខ្លះៗនឹងត្រូវបានណែនាំឱ្យស្គាល់ផងដែរ។

វិធីសាស្ត្រក្នុងការវិភាគលើអត្ថន័យ និងខ្លឹមសារនៃសាច់រឿងនិមួយៗនឹងត្រូវបានបង្ហាញ។ ការសិក្សាសង្កត់ទៅលើប្រធានបទសំខាន់ៗទាក់ទងទៅនឹង មិត្តភាព សេចក្តីស្រលាញ់ ការតស៊ូក្នុងជីវិត ការលើក លែងទោស ការសងសឹកសេចក្តីស្មោះត្រង់ការដឹងគុណ។ ល។ តាមរយៈសាច់រឿងនិមួយៗ ដែលបានសរសេរឡើង ដោយផ្ចិតផ្ចង់ ដោយអ្នកនិពន្ធល្បីៗនៅក្នុងពិភពលោក ដែលជាស្នាដៃសិល្បៈដ៏មានតំលៃគ្រប់ ពេលវេលានោះ នឹងណែនាំឱ្យស្គាល់ មិនត្រឹមតែអ្វីដែលមាននៅក្នុងពិភពនៃអក្សរសាស្ត្រប៉ុណ្ណោះទេ ថែមទាំងផ្តល់នូវមេរៀនបទពិសោធន៍ល្អៗសំរាប់សង្គមមនុស្សពិតៗផងដែរ។

គោលបំណងជាមូលដ្ឋាននៃមុខវិជ្ជានេះគឺដើម្បីអភិវឌ្ឍនូវជំនាញផ្នែកអក្សរសាស្ត្រដែលអាចយកមកប្រើប្រាស់សំរាប់ការគិតវិភាគទៅលើបញ្ហាទាំងនៅក្នុងពិភពអក្សរសាស្ត្រ និងពិភពនៃជីវិតពិត ហើយសំខាន់បំផុតដែលជាប់ទាក់ទងគ្នាផងដែរនោះគឺ ជួយជំរុញដល់ការសរសេរបែបវិភាគទៅលើបញ្ហានៃប្រធានបទផ្សេងៗ។ ការប្រើប្រាស់ឧបករណ៍ នៃអក្សរសាស្ត្រ (Literary Devices) សំរាប់យល់ដឹងពីតថភាពនៃសង្គមពីមនុស្សដែលរស់នៅក្នុងសង្គមនោះ និងពីបញ្ហាទាំងឡាយ ដែលគេជួបប្រទះ គឺជាវិធីមួយដ៏ប្រសើរក្នុងការ

យល់ដឹងពីសង្គមព្រោះអក្សរសិល្ប៍ជាកញ្ចក់ដែលតែងតែឆ្លុះបញ្ចាំងនូវសង្គម ។ការសិក្សាអក្សរសាស្ត្រមិនត្រឹមតែទទួលបាននូវចំណេះដឹង ផ្នែកអក្សរសាស្ត្រឡើយជាមួយគ្នានេះ ចំណេះដឹងផ្នែកភាសាអង់គ្លេសក៏ត្រូវបានពង្រឹងផងដែរ ។

## តំរូវការរបស់មុខវិជ្ជា

- ***ឯកសារ :*** ១-រឿងកណ្តុរស្រុកស្រែ និងកណ្តុរទីក្រុង ដោយ អេ ស៊ប (The Town Mouse and the Country Mouse by Aesop)

  ២-រឿងអាន់ដ្រូខល ដោយ អេ ស៊ប (Androcles by Aesop)

  ៣-រឿងថែមផេស  ដោយ សេក ស្ពៀរ (The Tempest by William Shakespeare)

  ៤-រឿងហែមលេត ដោយ សេក ស្ពៀរ (Hamlet by William Shakespeare)

  ៥-រឿងស្នេហាមួយ ដោយ អេរិច សេហ្គាល់ (Love Story by Eric Segal)

  ៦-រឿងដាវីដកូភឺហ្វៀល ដោយ ឆាល ឌីកែន (David Copperfield by Charles Dickens)

សៀវភៅ អក្សរសាស្ត្រអង់គ្លេសទៃទៀត គឺគួរតែអានបន្ថែម តែមិនតំរូវចាំបាច់សំរាប់ថ្នាក់នេះទេ។

- ***ការអាន :*** និស្សិតត្រូវអានជាមុននូវអត្ថបទ ឬ មេរៀនទាំងឡាយដែលបានកំណត់ មុនពេលពិភាក្សា ឬ សិក្សាក្នុងថ្នាក់ ។ កាលវិភាគសំរាប់មេរៀន និង បញ្ជីអត្ថបទ មេរៀនដែលត្រូវអាន គឺមានបង្ហាញជូននៅផ្នែកខាងក្រោម។  នៅពេលការសិក្សាក្នុងឆមាសដំណើរការ ខ្ញុំនឹងចែកជូនអត្ថបទបន្ថែមទៀត ដែលត្រូវតែអានមុនពេលចូលរៀនក្នុងថ្នាក់ ឬកិច្ចពិភាក្សាទាំងឡាយ។ បើអ្នកខកខានមិនបានចូលរៀនថ្នាក់ណា មួយនោះរឿងរ៉ាវល្អៗគួរចាប់អារម្មណ៍ ក៏បាត់បង់ផងដែរ។ និស្សិតក៏ត្រូវអាននិងស្រាវជ្រាវផងដែរសំរាប់កិច្ចការផ្ទះ និងកិច្ចស្រាវជ្រាវដែលគ្រូប្រគល់អោយ។ ចូររៀបចំពេលវេលា និងផែនការអោយបានត្រឹមត្រូវហ្មត់ហ្មងសំរាប់ខ្លួនអ្នកផ្ទាល់ តាំងពេលចាប់ផ្តើមដំបូងទៅ ដើម្បីជៀសវាងការតក់ស្លុតនូវអ្វីដែលត្រូវអានមានច្រើនសំបើមមុនពេលប្រលង។

**ម៉ោងសិក្សា និង វិធីសាស្ត្របង្រៀន :**

មុខវិជ្ជាសេដ្ឋកិច្ច HU101 ត្រូវបង្រៀនក្នុងលក្ខណៈពេញម៉ោង ហើយ មាន៤៨ម៉ោងសិក្សា ក្នុងរយៈពេល១៦សប្តាហ៍ ដែលត្រូវជួបជាមួយនិស្សិត។ ការបង្រៀននេះត្រូវបានបែងចែកតាមរូបភាពពីរយ៉ាងគឺ : *៣២ម៉ោងសំរាប់ថ្នាក់បឋកថា ១៦ម៉ោងសំរាប់ថ្នាក់ពិគ្រោះ ពិភាក្សាលើបញ្ហាចំងល់ផ្សេងៗ ទាក់ទងនឹងមេរៀននិមួយៗនៃមុខវិជ្ជានេះ។*

- ម៉ោងបឋកថា គឺធ្វើឡើងក្នុងរយៈពេល ២ម៉ោងក្នុងមួយសប្តាហ៍ ហើយម៉ោងបង្រៀនសំរាប់ថ្នាក់ពិគ្រោះ ពិភាក្សាធ្វើក្នុងរយៈពេល១ម៉ោងក្នុងមួយសប្តាហ៍។ និស្សិតដែលជ្រើសរើសមុខវិជ្ជានេះ សំរាប់វេនសិក្សានិមួយៗ ត្រូវចូលរៀនម៉ោងបឋកថា តែមួយរួមគ្នា។
- ចំនែកម៉ោងពិគ្រោះ ពិភាក្សា គឺជាក្រុមថ្នាក់តូចៗ ដែលរៀបចំបន្ថែមលើម៉ោងបឋកថា។ ក្នុងម៉ោងនេះ និស្សិតមានឱកាសសាកសួរដេញដោលជុំវិញបញ្ហាទាំងឡាយពួកគេមានលើខ្លឹមសារមេរៀន សំណួរនានា ។ល។ ហើយពេលនេះក៏ជាឱកាសដែលគ្រូបង្រៀននិងនិស្សិតរួមគ្នាដោះស្រាយបញ្ហា ចំលង់ផ្សេងៗ និង លើកចំណោទបញ្ហា វិភាគ ពិភាក្សា ផងដែរ។

## គោលការណ៍វាយតំលៃ

| | |
|---|---|
| - ពិភាក្សា និងរបាយការណ៏តាមក្រុម | ១៥% |
| - កិច្ចការស្រាវជ្រាវជាក្រុម | ១៥% |
| - វត្តមាន | ១0% |
| - កិច្ចការផ្ទាល់ខ្លួន | ១0% |
| - ការប្រឡងពាក់កណ្តាលឆមាស | ២0% |
| - ការប្រឡងឆមាស | ៣0% |
| សរុប | ១00% |

## មាតិកាមុខវិជ្ជា

| សប្តាហ៏ | ចំនងជើងរឿង | មាតិកា | ផ្សេងៗ |
|---|---|---|---|
| សប្តាហ៏ទី ១ | រឿងទី ១: រឿង កណ្តុរទីក្រុង និងកណ្តុរជនបទ (The Mouse and The Country Moudse) | I. ការណែនាំ<br>II. ការអានរឿងល្បើក និពន្ធ ដោយ អេសូប រឿងកណ្តុរទីក្រុង និងកណ្តុរ (The Town Mouse and the Country Mouse) | |
| សប្តាហ៏ទី ២ | រឿងទី ២: អេនទ្រូខល(Androcles) | អានរឿងល្បើក ដោយ អេសូប អនេទូខល | |
| សប្តាហ៏ទី | | អានអក្សរសិល្បបុរាណ ដោយសេក ស្ពៀរ | |

| | | | |
|---|---|---|---|
| ៣ | រឿងទី ៣:<br>The Tempest | រឿង ថេមពេស<br>- ជំពូក ១: ព្យុះកំណាចមួយ ( A frightening Storm)<br>- ជំពូក ២: ព្យុះប្រូសស្ពើរ ( Prospero’s storm)<br>- ជំពូក ៣: ដីកោះ (The Island)<br>- ជំពូក ៤: អេរីល (Ariel) | |
| សប្តាហ៍ទី ៤ | | - ជំពូក ៥: មារីនដា ធ្លាក់ក្នុងអន្លង់ស្នេហ៍<br>- ជំពូក ៦: អ្នកពិឃាត<br>- ជំពូក ៧: មនុស្សល្ងង់បីនាក់<br>- ជំពូក ៨: នៅឯរូង ប្រូសស្ពើរ<br>- ជំពូក ៩: ការចេញពីដីកោះ<br>- សេចក្តីសង្ខេប | |
| សប្តាហ៍ទី ៥ | រឿងទី ៣:<br>Hamlet | ការអានរឿងល្បើក និពន្ធ ដោយ សេកស្ពៀរ ហាំលែត<br>- ជំពូក ១: សេចក្តីទុក្ខព្រួយរបស់ព្រះអង្គម្ចាស់<br>- ជំពូក ២: ខ្មោចសំងាត់<br>- ជំពូក ៣: សេចក្តីល្ងង់ខ្លៅរបស់ ហាមលិត<br>- ជំពូក៤: ការសំដែង | |
| សប្តាហ៍ទី ៦ | | -ជំពូក៥: សេចក្តីទុក្ខព្រួយរបស់ព្រះអង្គម្ចាស់<br>-ជំពូក៦: គំរោងការស្តេច<br>-ជំពូក៧: ផ្នូរថ្មីមួយ<br>-ជំពូក៨: ការពិតត្រូវបានគេដឹង | |
| សប្តាហ៍ទី ៧ | រឿងទី ៥: Love Story | អត្ថបទអានសទីពីរឿងស្នេហាដែលជាចំណាប់អារម្មណ៍របស់មនុស្ស និពន្ធដោយលោក អេរិក សេហ្គាល<br>-អំពីអ្នកនិពន្ធ<br>-ជំពូក១: ការល្ងង់ និង មាន ឆ្លាតនិង ភាពក្រីក្រ | |

| | | | |
|---|---|---|---|
| | | -ជំពូក២: ឈាម និង ថ្ម | |
| សប្តាហ៍ទី ៨ | | -ជំពូក៣: យើងមានកម្មសិទ្ធទាំងអស់គ្នា<br>-ជំពូក៤: ភាពខុសប្លែកគ្នាពីរប្រភេទរបស់ឳពុក | |
| សប្តាហ៍ទី ៩ | | -ជំពូក៥: បីឆ្នាំដំបូង<br>-ជំពូក៦: លុយមិនអាចទិញអ្វីៗទាំងអស់បានឡើយ<br>-ជំពូក៧:បុរសមួយចំនួនមិនយំ | |
| សប្តាហ៍ទី ១០ | រឿងទី៦: David Copperfield | -ប្រលងពាក់កណ្តាលឆមាស<br>-អត្ថបទអានស្តីអំពីបុរាណកាលនិពន្ធដោយលោក ឆាលី ឌីកខិន ដេវីត ខូបភឺហ្វាល<br>-អំពីអ្នកនិពន្ធ<br>-ភាពវិលត្រឡប់នៃការគ្របដណ្តប់និង សេចក្តីផ្តើមនៃរឿង | |
| សប្តាហ៍ទី ១១ | | -ជំពូក១: វ័យកុមាររបស់ ដេវីត ខូបភឺហ្វាល<br>-ជំពូក២: ដេវីត ត្រូវបានបញ្ជូនទៅសាលារៀន | |
| សប្តាហ៍ទី ១២ | | -ជំពូក៣: ដេវីតជាក្មេងកំព្រា<br>-ជំពូក៤: ដេវីត និង មីងរបស់គាត់ | |
| សប្តាហ៍ ១៣ | | -ជំពូក៥: ដេវីតជួបមិត្តចាស់ម្តងទៀត<br>-ជំពូក៦: ដេវីតមានស្នេហា<br>-ថ្ងៃឈប់ទទួលយកកិច្ចការ | |
| សប្តាហ៍ទី ១៤ | | -ជំពូក៧: ដំណឹងល្អ និង ដំណឹងអាក្រក់របស់ដេវីត<br>-ជំពូក៨: ជីវិតថ្មីរបស់ដេវីត | |
| សប្តាហ៍ទី ១៥ | | -ជំពូក៩: ការរៀបការរបស់ដេវីត<br>-ជំពូក១០: ដេវីតនិង ការស្រាវជ្រាវ | |
| សប្តាហ៍ទី ១៦ | | -ជំពូក១០: ដេវីតនិងការស្រាវជ្រាវរបស់ ដេវីតខូបភឺហ្វាល( បន្ត) និពន្ធដោយលោក ឆាលី ឌីកខិន | |

| | | | |
|---|---|---|---|
| | | -សង្ខេប | |
| សប្ដាហ៍ទី ១៨ | | -ប្រលងបញ្ចប់ឆមាស | |